**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ...៨៥...អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ភារកិច្ច និង បេសកកម្មរបស់ក្រុមប្រឹក្សា កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

**សំរេច**

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ២.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌មានភារកិច្ច និងបេសកកម្មដូចតទៅ :

១- លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវទស្សនទាននៃកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និងយុទ្ធសាស្ត្រ គំរោងផែនការ ព្រមទាំងកម្មវិធីការងារ សំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃទស្សនទាននោះ

២- អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការនូវយុទ្ធសាស្ត្រ និងកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

៣- អនុម័តវិធានការចាំបាច់ទាំងឡាយ ក្នុងការដាក់អោយដំណើរការកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៤- ចេញសេចក្តីសំរេច និង សេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដើម្បីដឹកនាំ និងជំរុញដំណើរការកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៥- សំរបសំរួលបណ្តាសកម្មភាពរបស់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

៦- តាមដានការអនុវត្តកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួង ស្ថាប័នយុត្តិធម៌ ស្ថាប័ននានា និងរាយការណ៍ពីលទ្ធផលទទួលបាន ព្រមទាំងសំណូមពរពាក់ព័ន្ធនានា ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

៧- ទំនាក់ទំនង សំរបសំរួល ដើម្បីកេណ្ឌធនធានពីរដ្ឋ និងជំនួយអន្តរជាតិចាំបាច់

៨- ជំរុញ ការងារផ្សព្វផ្សាយពត៌មាន ស្តីពីសកម្មភាព និងសមិទ្ធិផលនៃការងារកំណែទំរង់នេះ

៩- បង្កលក្ខណៈ និងរៀបចំអោយមានការចូលរួមផ្តល់យោបល់ពីអង្គការក្រៅរដ្ឋាភិបាល និង សង្គម ស៊ីវិល នានា

១០- អនុវត្តរាល់ភារកិច្ច ផ្សេងៗទៀត ដែលឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋប្រគល់អោយ ។

**មាត្រា ៣.-**

ក្នុងការបំពេញភារកិច្ច និងបេសកកម្មខាងលើនេះក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសិទ្ធិប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានខ្ទង់ថវិកាដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៥.-**

ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវបានផ្គត់ផ្គង់ដោយ :

- វិភាគទាននៃថវិកាជាតិ
- បរិច្ចាគទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ស្ថាប័នដែលពាក់ព័ន្ធ និង សហប្រធាន ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី " ដើម្បីសុំហត្ថលេខា "

សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឌិត មន្ទី សុខ អាន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ